**រាជបណ្ឌិត្យសភាកម្ពុជា**
**វិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ**

*អត្ថបទស្រាវជ្រាវ ស្តីពី*

# ដើមត្នោត

## រុក្ខជាតិនិមិត្តរូបជាតិ និង ផលិតផលពីខ្លឹមត្នោត




*ដោយ ម៉ិល វាសនា*

*មន្ត្រីស្រាវជ្រាវនៃវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈនៃរាជបណ្ឌិត្យសភាកម្ពុជា*


*ខែកក្កដា ឆ្នាំ២០១៩*

# ដើមត្នោត ៖ រុក្ខជាតិនិមិត្តរូបជាតិ និង ផលិតផលពីខ្លឹមត្នោត

## សេចក្ដីផ្ដើម

ដើមត្នោតជាអត្តសញ្ញាណនៃទេសភាពទឹកដីរបស់ខ្មែរ ដោយស្ទើរគ្រប់ទីកន្លែងនៅក្នុងទឹកដីនេះ រួមទាំងអតីតទឹកដីរបស់ខ្មែរផង សុទ្ធសឹងមានអត្ថិភាពដើមត្នោតដុះនៅ។ ដោយតម្លៃនៃអត្តសញ្ញាណ វប្បធម៌ អរិយធម៌ និង ប្រវត្តិសាស្ត្រជម្មជាតិ ដើមត្នោតត្រូវបានចាត់បញ្ចូលជាប្រភេទរុក្ខជាតិនិមិត្តរូបជាតិ នៃព្រះរាជាណាចក្រកម្ពុជា ដោយព្រះរាជក្រឹត្យ លេខ នស/រកត/០៣០៥/១៤៩ ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ២០០៥ ស្ដីពីការកំណត់ប្រភេទសត្វនិងរុក្ខជាតិសម្រាប់និមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា។

ប្រភេទរុក្ខជាតិនេះបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្មែរ ដោយត្រូវប្រជាពលរដ្ឋខ្មែរប្រើជាប្រយោជន៍ច្រើនយ៉ាង តាំងពីគល់រហូតដល់ស្លឹក មានជាអាទិ៍ ដើមត្នោតត្រូវគេប្រើធ្វើទូក ធ្វើក្ដារផ្ទះ រនូតផ្ទះ, ផ្លែត្នោតទុំឬខ្ចីប្រើសម្រាប់ធ្វើនំឬបង្អែម, គមត្នោតត្រូវប្រើធ្វើជាបន្លែសម្ល, ទឹកប្រើធ្វើជាស្ករ និង ស្លឹកប្រើធ្វើជា មួក កន្ទេល ផ្តិត គ្រឿងវេចខ្ចប់ ដំបូលផ្ទះ ជញ្ជាំងផ្ទះ ។ល។

នៅជាងមួយទសវត្សរ៍ចុងក្រោយនេះ អត្ថប្រយោជន៍របស់ត្នោត បានឈានទៅរករូបភាពថ្មីផ្សេងទៀតគឺ ការផលិតជាវត្ថុសម្ភារៈសម្រាប់តុបតែងលម្អនិងសម្រាប់ប្រើប្រាស់មុខការផ្សេងៗ ដោយរួមមានទាំងវត្ថុសម្ភារៈខ្នាតតូច (ចាន ចង្កឹះ សម ស្លាបព្រា ផ្ទាំង ក្រឡម្រេច . . . ) និង វត្ថុសម្ភារៈខ្នាតធំ (តុ ទូ គ្រែ កៅអី សាឡុង . . . )។ ការកែច្នៃវត្ថុសម្ភារៈពីដើមត្នោតនេះមានទាំងក្នុងទម្រង់ជាលក្ខណៈគ្រួសារនិងជាលក្ខណៈសិប្បកម្ម។ ការផលិតជាលក្ខណៈគ្រួសារមានស្ថិតនៅតាមបណ្ដាខេត្តមួយចំនួន ដូចជា ខេត្តសៀមរាប ខេត្តបាត់ដំបង និង ពោធិ៍សាត់ ជាដើម។ ចំណែកឯការផលិតជាលក្ខណៈសិប្បកម្មក្នុងទ្រង់ទ្រាយធំគឺមាននៅក្នុងខេត្តពោធិ៍សាត់។ ការកកើតឡើងនូវសិប្បកម្មផលិតវត្ថុសម្ភារៈពីដើមត្នោតនេះបានធ្វើឱ្យមហាជនមានការព្រួយបារម្ភអំពីការបាត់បង់ដើមត្នោតដែលជាប្រភេទរុក្ខជាតិនិមិត្តរូបមួយរបស់សង្គមជាតិ។

អត្ថបទនេះនឹងលើកឡើងអំពីសិប្បកម្មផលិតវត្ថុសម្ភារៈផ្សេងៗពីដើមត្នោតនៅក្នុងខេត្តពោធិ៍សាត់ អំពីលក្ខណៈរបស់ដើមត្នោតដែលយកមកប្រើសម្រាប់ផលិត បច្ចេកទេសផលិត និងអត្ថប្រយោជន៍ផ្សេងៗ ដើម្បីជាមូលដ្ឋានក្នុងការជជែកពិភាក្សាគ្នាអំពីអត្ថប្រយោជន៍នៃដើមត្នោតសម្រាប់សង្គមបច្ចុប្បន្ន។

## សិប្បកម្ម សាន ពៅ នៅខេត្តពោធិ៍សាត់

*សិប្បកម្ម សាន ពៅ* ជាសិប្បកម្មធំមួយដែលផលិតវត្ថុសម្ភារៈផ្សេងៗពីដើមត្នោត។ សិប្បកម្មនេះមានទីតាំងស្ថិតនៅក្នុងភូមិបឹងឈូក ឃុំបឹងបត់កណ្ដាល ស្រុកបាកាន ខេត្តពោធិ៍សាត់ បង្កើតឡើងដោយ

លោក សាន ពៅ នៅឆ្នាំ២០០៤។ មូលហេតុដែលនាំឱ្យលោក សាន ពៅ ឈានទៅដល់ការបង្កើតសិប្បកម្មនេះឡើង គឺដោយសារលោកមើលឃើញខ្លឹមត្នោតល្អស្អាត, លោកមើលឃើញវត្ថុធាតុដើម (ដើមត្នោត) មានច្រើនដែលមិនទាន់មានការកែច្នៃយកទៅធ្វើជាប្រយោជន៍បានអស់លទ្ធភាព, លោកមើលឃើញពីជីវភាពរបស់ខ្លួន ក៏ដូចប្រជាជនដទៃទៀត គឺមានសភាពក្រលំបាកដោយធ្វើតែស្រែ ហើយត្រូវធ្វើចំណាកស្រុកស្វែងរកចំណូលបន្ថែមមកផ្គត់ផ្គង់ជីវភាពគ្រួសារនៅពេលទំនេរពីការងារធ្វើស្រែ។

មុនការបង្កើតសិប្បកម្មនេះ លោក សាន ពៅ បានចំណាយពេលប្រមាណពីរខែទៅសិក្សារៀនសូត្រអំពីរបៀបផលិតវត្ថុសម្ភារៈផ្សេងៗពីដើមត្នោតនេះ នៅនឹងគ្រួសារមួយក្នុងភូមិត្រាំសេះ(ភូមិក្បែរគ្នា) ដែលវាជាការផលិតជាលក្ខណៈគ្រួសារ ហើយវត្ថុដែលផលិតមានដូចជា វែកសម្ល កូនស្លាបព្រាកាហ្វេ និង ស្លាបព្រាបបរជាដើម។ ឧបករណ៍សម្រាប់ផលិតទៀតសោត គឺជាប្រភេទឧបករណ៍បែបប្រពៃណី មានជាអាទិ៍រណារដៃសម្រាប់អារដើមត្នោត ហើយប្រើពូថៅសម្រាប់ពុះដើមត្នោតជាចម្រៀកៗ ដែលមានសភាពយឺតយ៉ាវក្នុងការផលិត។

បន្ទាប់ពីទទួលបានចំណេះក្នុងការផលិតវត្ថុសម្ភារៈពីដើមត្នោតនេះ លោក សាន ពៅ បានចាប់យករបរនេះ ហើយបានស្រាវជ្រាវផលិតរបស់របរផ្សេងៗបន្ថែមទៀតដោយខ្លួនឯងជាបន្តបន្ទាប់ ដូចជា កែវ ចាន ផ្តិល និង ផ្ទាំងដាំបាយ ជាដើម។ *«ខ្ញុំបានស្រាវជ្រាវមើលវត្ថុដែលគេផលិតពីដែក ដីរ៉ា ពីឈើ និងពីវត្ថុធាតុផ្សេងៗហើយក៏ធ្វើតាមនេះ។ កាលនោះ ខ្ញុំមិនបានមើលតាមយូធូប(Youtube) និងមានគ្រឿងអេឡិចត្រូនិចដើម្បីស្រាវជ្រាវនោះទេ ខ្ញុំស្រាវជ្រាវមើលតែអ្វីដែលនៅជុំវិញខ្លួននិងមើលតាមទីផ្សារនូវវត្ថុប្រើប្រាស់ផ្សេងៗបន្ថែមទៀត»*[1]។

ទន្ទឹមគ្នានោះ លោក សាន ពៅ បានច្នៃរៀបជាម៉ាស៊ីនក្រឡឹងមួយពីម៉ាស៊ីនកិនស្រូវចាស់របស់លោក ប្រើសម្រាប់ក្រឡឹងជន្លាប់ ក្រឡឹងជើងទៀន ក្រឡឹងជើងបាត្រ និងវត្ថុសម្ភារៈផ្សេងទៀត ដើម្បីឱ្យមានភាពងាយស្រួលនិងលឿនរហ័សក្នុងការផលិត។ តាមពិត ម៉ាស៊ីនក្រឡឹងមានដាក់លក់នៅទីផ្សារ តែលោកមិនមានលទ្ធភាពទិញឡើយ ហើយម្យ៉ាងទៀត ប្រភេទម៉ាស៊ីនក្រឡឹងនៅទីផ្សារពុំសមស្របនឹងតម្រូវការផលិតបែបនេះឡើយ ដែលទាមទារឱ្យមានការកែច្នៃបន្ថែមទៀត។ ហេតុនេះលោកបានទិញនូវបំណែកណាដែលចាំបាច់ ហើយយកមកកែច្នៃរៀបជាមួយម៉ាស៊ីនកិនស្រូវចាស់មួយរបស់លោកដែលនៅសល់។ វត្ថុដំបូងគេដែលលោកផលិតដោយប្រើម៉ាស៊ីនក្រឡឹងនេះគឺ កែវសិក (កែវមានជើងតូចស្រឡូនប្រើសម្រាប់ដាក់ស្រា) និងក្រោយមកមានផលិតប៉ាន់តែ ស្រាក់ ជាបន្តបន្ទាប់មករហូតបានកាន់តែច្រើនប្រភេទឡើងៗដល់ជិតពាន់ប្រភេទនាពេលបច្ចុប្បន្ននេះ។ ដូច្នេះការបង្កើតបាននូវឧបករណ៍ទំនើប គឺបានជួយឱ្យការផលិតមានការរីកចម្រើនយ៉ាងលឿនលើមុខប្រភេទនៃវត្ថុសម្ភារៈត្រូវផលិត។

---

[1] សាន ពៅ អាយុ ៤១ ឆ្នាំ ជាម្ចាស់សិប្បកម្ម រស់នៅក្នុងភូមិបឹងឈូក ឃុំបត់កណ្តោល ស្រុកបាកាន ខេត្តពោធិ៍សាត់ (សម្ភាសថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៩)

ទោះយ៉ាងណា រយៈពេលប្រមាណ ៨ឆ្នាំដំបូង ក្រោយការកកើតសិប្បកម្មនេះ លោកបានខាតបង់ជាបន្តបន្ទាប់ ហើយពេលខ្លះ សូម្បីតែប្រាក់ខែកម្មករក៏មិនអាចផ្គត់ផ្គង់បានដែរ។ ជាដំណោះស្រាយចំពោះមុខ លោកបានបញ្ចុះតម្លៃឈ្នួលកម្មករជាបន្តបន្ទាប់ទៀត។ ជាមួយគ្នានោះ លោកនិងភរិយាតែងត្រូវសាច់ញាតិរិះគន់និងផ្តល់គំនិតឱ្យបញ្ឈប់ការងារនេះដោយលើកឡើងថា *ជាការងារមិនប្រទ្បំនឹងគេ ជាការងារឆ្កួត ដែលយកដើមត្នោតផលិតជារបស់របរផ្សេងៗ*...។ បន្ថែមលើនេះ នៅពេលចូលរួមការតាំងពិព័រណ៍ដាក់បង្ហាញនិងលក់ផលិតផលផ្សេងៗពីដើមត្នោតនេះ ក៏មានការរិះគន់ខ្លះៗថា ជាការបំផ្លាញដើមត្នោត ហើយនឹងធ្វើឱ្យដើមត្នោតផុតពូជនៅពេលអនាគត។ លោកស្រី ផាន គឿន ជាភរិយាលោកសាន ពៅ ដែលជាម្ចាស់សិប្បកម្មបានលើកឡើងថា នៅពេលតាំងពិព័រណ៍ម្តងៗ បុគ្គលខ្លះមិនត្រឹមតែរិះគន់វាយប្រហារត្រឹមម្ចាស់សិប្បកម្មប៉ុណ្ណោះទេ គឺថែមទាំងវាយប្រហារដល់មហាជនជាអ្នកទិញទៀតផងដូចជាថា « *បើអ្នកណាជួយទិញរបស់ទាំងនេះ គឺហាក់ដូចជារួមចំណែកបំផ្លាញដើមត្នោតដែរ* »[2]។ ការរិះគន់នេះបានធ្វើឱ្យប៉ះពាល់ដល់ចំណាប់អារម្មណ៍របស់មហាជនឬអ្នកទិញចំពោះផលិតផលពីដើមត្នោតនេះ ដែលពេលខ្លះគឺទាមទារឱ្យម្ចាស់សិប្បកម្មបកស្រាយពន្យល់អំពីលក្ខណៈបច្ចេកទេស និងប្រភេទដើមត្នោត ដែលត្រូវយកមកផលិតជាវត្ថុសម្ភារៈផ្សេងៗទាំងនេះ។

ទោះជាជួបនូវបញ្ហាជាច្រើនក្តី តែលោកពុំបានបញ្ឈប់ការងារនេះឡើយ ហើយបានលក់គោក្របីនិងលក់ដីស្រែស្ទើរគ្មានសល់ ដើម្បីបន្តដំណើរការសិប្បកម្មឈានទៅសម្រេចមហិច្ឆិតារបស់លោក។ ដោយមើលឃើញពីទឹកចិត្តនិងការតស៊ូរបស់លោកផ្ទាល់ កម្មករទាំងអស់របស់លោកនៅតែអំណត់តស៊ូជាមួយលោក។ «*គាត់ដឹងស្ថានភាពនិងដឹងចិត្តខ្ញុំ ហេតុនេះពួកគាត់នៅតែតស៊ូជាមួយខ្ញុំ*» [3]។ លោកសាន ពៅ នៅតែមើលឃើញថា វត្ថុដែលលោកផលិតបានពីដើមត្នោតគឺជាវត្ថុដែលល្អស្អាត និងមានតម្លៃគួរឱ្យស្រឡាញ់។ លោកបានលើកឡើងថា *«សូម្បីកូនស្លាបព្រាកាហ្វេ ពេលវាត្រូវពន្លឺភ្លើងទៀន ឬ ត្រូវភ្លើងអគ្គិសនី ខ្ញុំស្រឡាញ់ខ្លាំងណាស់ ខ្ញុំសឹងតែចាត់ទុកវាស្មើនឹងគ្រាប់ពេជ្រសម្រាប់ខ្ញុំ ហេតុនេះខ្ញុំនៅតែមានទឹកចិត្តនឹងបន្តកិច្ចការនេះតទៅទៀត។ ខ្ញុំគិតថា ខ្ញុំស្រឡាញ់ ហេតុនេះច្បាស់ជានឹងមានអ្នកស្រឡាញ់វាដែរហើយ»*[4]។

ដោយក្តីស្រឡាញ់ ការអំណត់តស៊ូ និងការជម្នះឧបសគ្គជាច្រើន សិប្បកម្មនេះចាប់ផ្តើមមានការទទួលស្គាល់ ការគាំទ្រ និង ទទួលបានជោគជ័យជាបន្តបន្ទាប់។ លោកបានជ្រើសរើសកម្មករបន្ថែមជាបន្តបន្ទាប់ ដើម្បីពន្លឿនការងារផលិតឱ្យទាន់តាមការបញ្ជាទិញពីអតិថិជន។ ទន្ទឹមគ្នានេះ លោកបានកែច្នៃ

---

[2] ផាន គឿន អាយុ៤៣ឆ្នាំ រស់នៅក្នុងភូមិបឹងឈូក ឃុំបត់កណ្តោល ស្រុកបាកាន ខេត្តពោធិ៍សាត់។ (សម្ភាសថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៩)

[3] សាន ពៅ អាយុ ៤១ ឆ្នាំ ជាម្ចាស់សិប្បកម្ម រស់នៅក្នុងភូមិបឹងឈូក ឃុំបត់កណ្តោល ស្រុកបាកាន ខេត្តពោធិ៍សាត់ (សម្ភាសថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៩)

[4] សាន ពៅ អាយុ ៤១ ឆ្នាំ ជាម្ចាស់សិប្បកម្ម រស់នៅក្នុងភូមិបឹងឈូក ឃុំបត់កណ្តោល ស្រុកបាកាន ខេត្តពោធិ៍សាត់ (សម្ភាសថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៩)

និងទិញឧបករណ៍ថ្មីៗបន្ថែមទៀតកាន់តែច្រើនឡើងផងដែរ។ បច្ចុប្បន្ននេះ សិប្បកម្ម សាន ពៅ មាន កម្មករប្រមាណជាង១២០នាក់ ហើយប្រាក់ឈ្នួលកម្មករមានចាប់ពីជាង ១០០ដុល្លារ (សម្រាប់អ្នកមិនទាន់ចេះ) រហូតដល់៣៥០ដុល្លារ ទៅតាមប្រភេទនៃការងារនិងចំណេះជំនាញ។

## វត្ថុធាតុដើមសម្រាប់ការផលិត

និយាយដោយចំពោះ វត្ថុសម្ភារៈប្រើប្រាស់ វត្ថុអនុស្សាវរីយ៍ និង គ្រឿងវត្ថុតុបតែងលម្អទាំងឡាយខាងលើគឺត្រូវផលិតពីខ្លឹមត្នោត មិនមែនផលិតពីគ្រប់ផ្នែកនៃដើមត្នោតនោះទេ ហើយមិនមែនគ្រប់ដើមត្នោតសុទ្ធតែមានខ្លឹមដែលអាចយកមកប្រើការសម្រាប់ការផលិតបាននោះដែរ។ គេត្រូវចេះមើលនិងជ្រើសរើសយកដើមត្នោតដែលចាស់និងមានខ្លឹម ទើបអាចយកវាមកផលិតជាវត្ថុសម្ភារៈផ្សេងៗបាន។ ការផលិតវត្ថុសម្ភារៈផ្សេងៗពីខ្លឹមត្នោតដែលមានជាប់ស្រោយ វានឹងងាយធ្វើឱ្យមានមេស៊ីឬធ្វើឱ្យវត្ថុប្រើប្រាស់នោះអន់គុណភាព ឆាប់ខូចខាត រក្សាទុកមិនបានយូរ។ ហេតុនេះ ក្នុងការផលិត គឺគេត្រូវចៀរ ឬក្រឡឹងសាច់ស្រោយទាំងឡាយចោលឱ្យអស់។

ដើមត្នោតមានខ្លឹមច្រើនឬតិច គឺអាស្រ័យលើអាយុកាលនៃដើមត្នោតនោះ។ ប្រសិនបើដើមត្នោតចាស់ មានអាយុច្រើន នោះវានឹងមានខ្លឹមច្រើន (ខ្លឹមក្រាស់) ឯដើមត្នោតខ្ចី អាយុតិច នោះវានឹងមានខ្លឹមតិច (ខ្លឹមស្តើង) ហើយមានស្រោយច្រើន។ ដើមត្នោតដែលមានអាយុកាលចាប់ពី១០០ឆ្នាំឡើងទៅ ទើបមានខ្លឹមល្អសម្រាប់ការផលិតជាវត្ថុសម្ភារៈផ្សេងៗ។



ដើមត្នោតគ្មានខ្លឹម



ដើមត្នោតមានខ្លឹមសងខាងនិងមានស្រោយនៅកណ្ដាល

ជាទូទៅ គេអាចសម្គាល់ដើមត្នោតមានខ្លឹមឬដើមត្នោតចាស់ ដោយដើមត្នោតនោះមានកម្ពស់ចាប់ពី ២៥ម៉ែត្រឡើងទៅ គ្មានធាង គ្មានផ្លែ គ្មានផ្កា ដើមមានសភាពរៀវតូច ហើយមានសម្បកក្រាស់មានស្និមនិងមានស្លែកាន់។ ប្រសិនបើមានស្លែពីគល់ឡើងដល់ត្រឹមណានោះខ្លឹមត្នោតក៏មានដល់ត្រឹមនោះដែរ។ ទោះបីដើមត្នោតខ្លះខ្ពស់សន្លឹម តែបើវាមិនមានស្លែកាន់ឬសម្បុរឡើងស្និមទេ នោះដើមត្នោតនោះក៏អាចមិនមានខ្លឹមដែរ។

តាមលោក សាន ពៅ ជាម្ចាស់សិប្បកម្ម ដើមត្នោតដែលមានអាយុចាស់ខ្លាំង គឺវាមានខ្លឹមពេញមួយដើមទាំងមូលពីគល់ដល់ចុង ដោយមិនមានស្រាយនោះទេ។ ដើមត្នោតដែលមានខ្លឹមពេញមួយដើមបែបនេះគឺងាយប្រឈមនឹងការបាក់ធ្លាក់ខ្លាំងណាស់ ដោយវាអាចធ្លាក់បាក់ជា ២ ឬ ៣ កំណាត់ក៏មានព្រោះវាមានសភាពស្រួយ ដោយវាលែងមានសរសៃស្ទូលកណ្តាលដើម(ស្រាយ)ដែលជាផ្នែកស្វិតអាចជួយទប់ទល់នឹងខ្យល់បក់បោកបាន។ ត្នោតដែលមានខ្លឹមពេញមួយដើមពីគល់ដល់ចុងបែបនេះ គឺមានកម្ពស់ខ្ពស់និងមានអាយុមិនក្រោមប្រាំរយឆ្នាំនោះទេ ហើយត្នោតប្រភេទនេះកម្រមានផ្កា ធាង ឬ ផ្លែទៀតណាស់ [5]។ ដូច្នេះ វាហាក់មិនអាចប្រើជាប្រយោជន៍ផ្សេងៗសម្រាប់កសិករបានទៀតឡើយ។ ម្យ៉ាងបើទោះបីជាវាអាចនៅមានធាង ផ្កា ផ្លែ ក៏ដោយ ក៏ប្រជាជនមិនហ៊ានឡើងទាញប្រយោជន៍ពីវាទៀតដែរ ដោយសារវារៀវខ្ពស់ ដែលងាយបង្កជាគ្រោះថ្នាក់ផ្សេងៗ។



ជើងក្បាលគ្រែធ្វើអំពីខ្លឹមត្នោតពេញមួយដើម

ទោះបីដើមត្នោតមានខ្លឹមពេញមួយដើមមានសភាពស្រួយ ប្រឈមនឹងការងាយបាក់ធ្លាក់ក្តី តែខ្លឹមវាមានសភាពរឹងប្រៀបដូចដែក ហើយពេលគេយកខ្លឹមនោះមកផលិតជាវត្ថុសម្ភារៈផ្សេងៗ គឺមាន

[5] សាន ពៅ អាយុ៤១ ឆ្នាំ ជាម្ចាស់សិប្បកម្ម រស់នៅក្នុងភូមិបឹងឈូក ឃុំបត់កណ្តោល ស្រុកបាកាន ខេត្តពោធិ៍សាត់ (សម្ភាសថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៩)

សភាពជាប់មាំល្អណាស់ មិនប្រេះបែកនោះឡើយ។ ជាទូទៅ គេប្រើខ្លឹមត្នោតនេះសម្រាប់ផលិតគ្រឿងធំៗ ដូចជា ជើងគ្រែ ជើងតុ ផ្ទិលធំៗ និង ក្តារក្រាល ជាដើម។

ត្នោតមានពីរប្រភេទគឺ ត្នោតមេ និង ត្នោតឈ្មោល។ ត្នោតមេមានជ្រាំងឬសរសៃពណ៌ខ្មៅនិងពណ៌សធំៗលាយចម្រុះគ្នា ហើយមានសាច់ខ្លឹមមិនសូវហាប់ណែន។ ឯត្នោតឈ្មោលមានជ្រាំងឬសរសៃពណ៌ខ្មៅញឹកល្អិត និងមានសាច់ខ្លឹមហាប់ណែន។ ដូច្នេះ ត្នោតឈ្មោលមានគុណភាពខ្លឹមល្អជាងត្នោតមេ ទោះបីជាត្នោតទាំងពីរប្រភេទនេះមានអាយុដំណាលគ្នាក្តី។




ជាទូទៅ គេអាចបែងចែកត្នោតមួយដើមជាបីផ្នែកទៅតាមពណ៌សម្បុរខ្លឹមរបស់វា គឺខ្លឹមផ្នែកខាងគល់មានសម្បុរក្រហមស្រគាំ ខ្លឹមផ្នែកកណ្តាលមានសម្បុរខ្មៅ និង ខ្លឹមផ្នែកខាងចុងមានសម្បុរសស្លេក។ ជាទូទៅ គេប្រើខ្លឹមត្នោតនៅផ្នែកខាងគល់សម្រាប់ផលិតជាថាំងតែ ស្រាក់ ក្អម ផ្ទាំងបាយ ផ្ទិល . . . , គេប្រើខ្លឹមត្នោតផ្នែកកណ្តាល (ចំពោះដើមត្នោតមានខ្លឹមពេញមួយដើម) សម្រាប់ផលិតជាជើងគ្រែ ជើងតុ ផ្ទិលធំៗ ថូផ្កាធំ សាឡុង ហង្សតេ ប៉ោអ៊ី កៅអី ក្តារតុ ក្តារគ្រែ ជញ្ជាំង និង ការ៉ូក្រាលបាតក្រោម ជាដើម ហើយគេប្រើខ្លឹមត្នោតនៅផ្នែកខាងចុងដែលមានសភាពស្តើង សម្រាប់ផលិតជាវត្ថុតូចៗ ដូចជា វែកឆា ចង្កឹះ និង កូនស្លាបព្រាកាហ្វេ ជាដើម។ ប៉ុន្តែប្រសិនបើខ្លឹមត្នោតនៅផ្នែកខាងចុងក្រាស់ នោះគេក៏អាចប្រើវាសម្រាប់ផលិតជាវត្ថុសម្ភារៈធំៗដែរ។




ដើមត្នោតសម្រាប់ដំណើរការផលិតវត្ថុសម្ភារៈផ្សេងៗនៅសិប្បកម្ម សាន ពៅ រហូតមកដល់បច្ចុប្បន្ននេះ គឺបានមកពីការផ្ដល់ឱ្យពីការសុំ និង ពីការទិញដើមត្នោតដែលគេត្រូវកាប់ចោលដោយប្រការផ្សេងៗ មានជាអាទិ៍ ដើមត្នោតទើសខ្សែភ្លើង ដើមត្នោតទើសនៅមុខផ្ទះ មុខមន្ទីរពេទ្យ ក្នុងមន្ទីរពេទ្យ ឬមុខវត្តអារាម ដើមត្នោតដុះក្នុងដីស្រែដែលម្ចាស់យល់ថាខាតដីស្រែឬខ្លាចបាក់ធ្លាក់ជាងធ្វើឱ្យខូចខាតស្រូវ ដើមត្នោតដែលគេកាប់ឬឈូសចោលដោយតម្រូវការអភិវឌ្ឍ ដើមត្នោតចាស់កោងដែលម្ចាស់ខ្លាចរលំបង្កគ្រោះថ្នាក់ ដើមត្នោតងាប់បាក់ជួល ដើមត្នោតត្រូវរន្ទះបាញ់ ដើមត្នោតចាស់ប្រើជាប្រយោជន៍មិនកើតដូចជាខ្ពស់ពេក ម្ចាស់លែងហ៊ានឡើង ឬ ត្នោតចាស់បាក់មែកលែងលូតលាស់ ជាដើម ។

ចំពោះដើមត្នោតដែលបានកាត់រួចនិងដឹកមកដល់កន្លែងសិប្បកម្ម គេត្រូវកាត់ច្រៀកវាជាចម្រៀកៗទៅតាមទំហំដែលគេត្រូវការ ដោយមិនទុកដើមត្នោតទាំងមូលនោះចោលរហូតដល់រយៈពេល១ខែឡើយ ព្រោះដើមត្នោតនោះនឹងប្រែជារឹងខ្លាំងពិបាកកាត់ច្រៀក( អាចធ្វើឱ្យបាក់មុខរណា ) ហើយជាងនេះទៀត គឺដើមត្នោតនោះអាចប្រេះស្រាំ ដែលនាំឱ្យខូចប្រើការលែងកើត។

## ប្រភេទវត្ថុសម្ភារៈផលិតបាន

បច្ចុប្បន្ន សិប្បកម្មនេះបានផលិតវត្ថុសម្ភារៈប្រើប្រាស់ វត្ថុអនុស្សាវរីយ៍ គ្រឿងវត្ថុតុបតែងលម្អ និងគ្រឿងសង្ហារិមផ្សេងៗរហូតដល់ជិតពាន់មុខ ដោយរាប់បញ្ចូលទាំងប្រភេទវត្ថុតែមួយ តែមានច្រើនទម្រង់ឬ

ច្រើនខ្នាតទំហំផងដែរ។ គ្រឿងវត្ថុសម្ភារៈទាំងនោះមានដូចជា ស្លាបព្រា (ស្លាបព្រាបាយ ស្លាបព្រាកាហ្វេ ស្លាបព្រាបបរ ស្លាបព្រាខ្នាតធំប្រើសម្រាប់ចូកបន្លែជាដើម) ចាន(កូនចាន ចានគោមតូច ចានគោមធំ ចានសំប៉ែត និងប្រភេទចានសម្រាប់ដាក់បន្លែ ...) ឆ្នាំង ពែងតែ កែវ (កែវស្រាសុិច កែវធម្មតាមានដៃកាន់ កែវគ្មានដៃកាន់ ...) ចង្កឹះ សម (ខ្នាតតូច ខ្នាតល្មម ខ្នាតធំ) វែក (វែកដួសបាយ វែកជ្រួយបាយ វែកសម្ល វែកឆា) ក្រឡម្រេច (ខ្នាតតូច ខ្នាតធំ) ប្រដាប់ដាក់ឈើចាក់ធ្មេញ ត្បាល់ ឃ្លោក ស្រាក់ ទូក (ខ្នាតតូច ខ្នាតល្មម ខ្នាតធំ) ថាំងតែ ថាស ប្រអប់ដាក់ស្រា និង ប្រអប់ដាក់ក្រដាសជូតមាត់ ជាដើម។ ចំណែកឯវត្ថុ ឬគ្រឿងសង្ហារិមខ្នាតធំ មានដូចជា គ្រែ តុ (តុធ្វើការ តុមូល តុប្រជុំ តុខ្នាតខ្លី តុខ្នាតវែង ...) ទូ (ទូខោអាវ ទូតាំង)  សាឡុង (មានច្រើនម៉ូត) ហង្សតេ (មានច្រើនម៉ូត)  កៅអី (មានច្រើនម៉ូត) បង្កាន់ដៃជណ្ដើរផ្ទះ កូនក្រឡឹង និង ការ៉ូក្រាលផ្ទះ ជាដើម។

ម្ចាស់សិប្បកម្ម លោក សាន ពៅ បានអះអាងថា គ្រឿងសម្ភារៈខ្នាតល្មមឬខ្នាតធំ ដូចជា តុ ទូ សាឡុង និង គ្រែ ជាដើម គឺអាចប្រើបានរហូតដល់រយឆ្នាំ ដោយមូលហេតុមួយចំនួនគឺ ទី១ គ្រឿងសម្ភារៈទាំងនោះផលិតពីខ្លឹមត្នោតស្ងួតល្អ ដែលមានសភាពរឹងជាប់ប្រៀបដូចដែក , ទី២ ដំណាប់តំណភ្ជាប់មានប្រើការញ៉ីឈ្មោលនិងកម្ទេចអាចម៍រណារដាក់ចូលណែន និង ទី៣ គ្រឿងសម្ភារៈទាំងនោះជាគ្រឿងប្រើនៅក្នុងផ្ទះ ដែលមិនត្រូវថ្ងៃ មិនហាលភ្លៀង មិនហាលខ្យល់នោះទេ។ ហេតុនេះ គ្រឿងសម្ភារៈទាំងនេះនឹងអាចប្រើរហូតតជំនាន់មនុស្សបាន។


សម្ភារៈខ្នាតតូចផលិតពីខ្លឹមត្នោត


សម្ភារៈខ្នាតធំផលិតពីខ្លឹមត្នោត




គ្រែបារាំងនិងគ្រែម៉ុងធ្វើពីខ្លឹមត្នោត




កៅអីនិងហង្សតេធ្វើពីខ្លឹមត្នោត




ទូជាប់ជញ្ជាំង តុ សាឡុង និង បង្កាន់ដៃ ធ្វើពីខ្លឹមត្នោត

## ឧបករណ៍សម្រាប់ផលិត

គ្រឿងឧបករណ៍សម្រាប់ផលិតវត្ថុប្រើប្រាស់និងវត្ថុអនុស្សាវរីយ៍ផ្សេងៗក្នុងសិប្បកម្មនេះមានដូចជា ម៉ាស៊ីនដោង ម៉ាស៊ីនច្រៀក តាបច្រៀក ម៉ាស៊ីនរៀល ម៉ូទ័រលក ម៉ូទ័រឈូស តាបឈូស ម៉ូទ័រខាត់ ម៉ាស៊ីនក្រឡឹង និង ម៉ាស៊ីនខាត់ចង្កឹះ ជាដើម។ នៅជំហានដំបូង គេប្រើម៉ាស៊ីនដោង បន្ទាប់មកគេប្រើម៉ាស៊ីនច្រៀកឬម៉ាស៊ីនរៀលទៅតាមប្រភេទវត្ថុសម្ភារៈត្រូវផលិត។ ប្រសិនបើសិនវត្ថុសម្ភារៈនោះត្រូវក្រឡឹង គឺចម្រៀកត្នោតនោះចូលទៅផ្នែកម៉ាស៊ីនក្រឡឹង តែបើវត្ថុនោះត្រូវការខាត់ គឺវាចូលទៅផ្នែកម៉ាស៊ីនខាត់។ ដោយឡែក ម៉ាស៊ីនផលិតចង្កឹះគឺមានលក្ខណៈពាក់កណ្តាលស្វ័យប្រវត្តិ ដោយវាអាចចិត លុញ កាត់ និងខាត់ចម្រៀកត្នោតឱ្យក្លាយជាចង្កឹះតែម្តង ដោយប្រើកម្លាំងមនុស្សតែបន្តិចបន្តួចប៉ុណ្ណោះ។ ម៉ាស៊ីនផលិតចង្កឹះនេះមានតម្លៃ ៥០០០ដុល្លារសហរដ្ឋអាម៉េរិក។ ជារួម ក្នុងដំណើរការផលិតមានផ្នែកជាច្រើនដោយទទួលខុសត្រូវទៅតាមជំនាញនិងប្រភេទវត្ថុសម្ភារៈដែលត្រូវផលិត។

បច្ចុប្បន្ននេះ សិប្បកម្ម សាន ៣ មានគ្រឿងឧបករណ៍សម្រាប់ដំណើរការសិប្បកម្មទាំងមូលច្រើនប្រភេទ ហើយគ្រឿងឧបករណ៍ទាំងនេះបានមកពីការសន្សំនិងការពង្រីកដំណើរការផលិតជាបន្តបន្ទាប់ ចាប់តាំងពីសិប្បកម្មនេះកកើតឡើង។



សកម្មភាពកម្មករខាត់វត្ថុសម្ភារៈដោយប្រើម៉ូទ័រខាត់



ម៉ាស៊ីនច្រៀក



ម៉ាស៊ីនក្រឡឹង





ចង្កឹះដែលផលិតចេញពីម៉ាស៊ីនផលិតចង្កឹះ និង ម៉ាស៊ីនខាត់ចង្កឹះ

## បច្ចេកទេសប្រើថ្នាំ

ក្រោយពីវត្ថុសម្ភារៈទាំងឡាយផលិតបានចេញជារូបរាងរួចស្រេចហើយ វត្ថុសម្ភារៈទាំងនោះត្រូវឆ្លងកាត់បច្ចេកទេសប្រើថ្នាំនិងខាត់ឱ្យភ្លឺរលោងបួនដំណាក់កាលទៀត មុននឹងវត្ថុសម្ភារៈទាំងនោះអាចបញ្ចេញទៅលើទីផ្សារឬប្រគល់ឱ្យអតិថិជន។ ដំណាក់កាលទាំងបួននោះគឺ៖ ទី១ ប្រើថ្នាំ BL លាយជាមួយសាំងក្រអូប ហើយជូតលាបលើវត្ថុសម្ភារៈដែលផលិតរួច, ទី២ ប្រើថ្នាំ Selex លាយជាមួយសាំងក្រអូបនិងថ្នាំសាអាប់៥០% ហើយជូតលាបលើវត្ថុសម្ភារៈដើម្បីជួយរក្សាពណ៌ធម្មជាតិដើម មិនឱ្យភ្លឺរលោងពេក, ទី៣ រំលីងវត្ថុសម្ភារៈលាបហើយទាំងនោះនឹងទៀន ប្រេងសណ្តែក និង ទី៤ ខាត់វត្ថុសម្ភារៈទាំងនោះ

ដោយប្រើដក់ម៉ូទ័រ[6] ។ យើងសង្កេតឃើញថា គ្រឿងសង្ហារិមដែលផលិតពីខ្លឹមត្នោតនៅក្នុងសិប្បកម្មនេះ គឺមិនមានបាញ់ថ្នាំឱ្យប្រាសចាកពីពណ៌ធម្មជាតិរបស់ត្នោតដូចគ្រឿងសង្ហារិមដែលផលិតពីឈើឡើយ។



សកម្មភាពកម្មករផ្នែកខាត់សម្អាតនិងប្រើថ្នាំលាបឱ្យភ្លឺស្អាត

## អត្ថប្រយោជន៍សម្រាប់សហគមន៍

ភាពជោគជ័យនៃដំណើរការសិប្បកម្មផលិតវត្ថុសម្ភារៈផ្សេងៗពីដើមត្នោតនេះ បានរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រនិងការធ្វើចំណាកស្រុករបស់ប្រជាជនកម្ពុជា ជាពិសេសចំពោះប្រជាជននៅក្នុងសហគមន៍ផ្ទាល់។ រហូតមកដល់បច្ចុប្បន្ននេះ សិប្បកម្មមានកម្មករជាង១២០នាក់ (កំពុងត្រូវការជ្រើសរើសកម្មករបន្ថែមទៀត) ដែលមានប្រាក់ខែចាប់ពីជាង ១០០ដុល្លារសហរដ្ឋអាម៉េរិក[7] រហូតដល់ ៣៥០ដុល្លារសហរដ្ឋអាម៉េរិក ហើយក៏នឹងដំឡើងជាបន្តបន្ទាប់ទៀតទៅតាមកម្រិតចំណេះជំនាញនិងប្រភេទការងារជាក់ស្តែងផងដែរ។ កម្មករទាំងនេះភាគច្រើនបំផុតគឺជាប្រជាពលរដ្ឋរស់នៅក្នុងភូមិនិងអ្នកភូមិក្បែរខាង ហើយក្រៅពីនេះក៏មានកម្មករខ្លះមកពីស្រុកដទៃនៅក្នុងខេត្តនិងមកពីខេត្តដទៃខ្លះដែរ[8]។ ជនពិការដែលជាបេក្ខភាពពិបាកស្វែងរកការងារធ្វើក៏ត្រូវបានលើកទឹកចិត្តឱ្យធ្វើការនៅក្នុងសិប្បកម្មនេះដែរ។

ក្នុងការធ្វើការងាររកប្រាក់ចំណូលនៅក្នុងសិប្បកម្មនេះ ប្រជាជនមិនមែនអាចធ្វើបានតែនៅក្នុងរដូវប្រាំងដែលទំនេរពីការងារធ្វើស្រែនោះទេ តែពួកគាត់ក៏អាចធ្វើវាបាននៅក្នុងរដូវវស្សាដែលជារដូវធ្វើស្រែផង

6 ស្រី ហៃ ភេទស្រី អាយុ៤៩ឆ្នាំ ជាកម្មករធ្វើការក្នុងសិប្បកម្ម រស់នៅក្នុងភូមិបឹងឈូក ឃុំបត់កណ្តាល ស្រុកបាកាន ខេត្តពោធិ៍សាត់ (សម្ភាសថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៩)។

[7] ប្អូនស្រីឈ្មោះ គៀន មិកា និង ម៉ន សុខរីម ដែលទើបចូលមកធ្វើការក្នុងសិប្បកម្មនេះ ទទួលបានប្រាក់ខែ ៤៥០ ០០០រៀល។

[8] ចំពោះកម្មករមកពីស្រុក-ខេត្តឆ្ងាយ ម្ចាស់សិប្បកម្មផ្គត់ផ្គង់បាយទឹកជូនមួយថ្ងៃបីពេល(ព្រឹក ថ្ងៃ ល្ងាច) និងថែមទាំងផ្តល់កន្លែងស្នាក់នៅ និងការប្រើប្រាស់ទឹកភ្លើងដោយពុំគិតឡើយ។

ដែរ។ បើយោងតាមលោក ប៉ាត់ អាន[9] បានលើកឡើងថា ម្ចាស់សិប្បកម្មតែងអនុញ្ញាតឱ្យកម្មករឈប់សម្រាករយៈពេល ១០ថ្ងៃ នៅរដូវធ្វើស្រែ ដើម្បីឱ្យកម្មករមានលទ្ធភាពធ្វើការងារស្រែរបស់ខ្លួន។ បច្ចុប្បន្នការធ្វើស្រែមិនចំណាយពេលវេលាយូរដូចពេលមុនឡើយ ដោយប្រជាជននិយមប្រើវិធីព្រោះស្រូវលែងសាប ដក ស្ទូង ដូចវិធីសាស្ត្រពីមុនទៀតហើយ ព្រមទាំងប្រើគ្រឿងម៉ាស៊ីនសម្រាប់ការភ្ជួររាស់ដី និងការច្រូត បោកបែន។ ដោយឡែក ការដាក់ជីស្រែ គឺកម្មករនៅក្នុងភូមិអាចឆ្លៀតពេលធ្វើបាននៅពេលម៉ោងឈប់សម្រាក។

ការមានការងារធ្វើ មានប្រាក់ចំណូលបន្ថែមលើរបរធ្វើស្រែជាមូលដ្ឋានរបស់ប្រជាជននៅក្នុងសហគមន៍[10] ដែលពេលខ្លះជួបគ្រោះធម្មជាតិពុំទទួលបានទិន្នផលល្អ បានជួយឱ្យប្រជាជនជាច្រើននាក់ច្រើនគ្រួសារនៅក្នុងភូមិ លែងធ្វើចំណាកស្រុកទៅប្រទេសថៃឬទៅបណ្តាខេត្តនៅជាប់ព្រំដែនថៃ ដើម្បីស៊ីឈ្នួលដកដំឡូង កាប់ពោត ការងារសំណង់ និង ការងារផ្សេងៗទៀត ដែលអាចជួបនូវបញ្ហាជាច្រើន។ ជាក់ស្តែង លោក ភោគ ជួន ដែលធ្វើការនៅក្នុងសិប្បកម្មនេះបានលើកឡើងថា «*តាំងពីមានសិប្បកម្មនេះមក គឺជួយដល់អ្នកភូមិច្រើន មិនសូវមានអ្នកដើរចេញចោលផ្ទះសម្បែងទៅរកការងារធ្វើនៅស្រុកឆ្ងាយនោះទេ។ មុននេះអ្នកភូមិចេញទៅច្រើនឡើងស្ងាត់ភូមិ* »[11] ។

ប្រាក់ចំណូលទទួលបានពីការធ្វើការងារនៅក្នុងសិប្បកម្មនេះ ក្រៅពីការជួយផ្គត់ផ្គង់ជីវភាពគ្រួសារប្រចាំថ្ងៃ វាក៏បានរួមចំណែកយ៉ាងសំខាន់ក្នុងការជួយសងបំណុលដែលកម្មករក្នុងសហគមន៍បានជំពាក់ធនាគារ ឬភ្នាក់ងារកស៊ីឯកជនដែរ។ ជាទូទៅ ក្រៅពីការជំពាក់បំណុលដោយតម្រូវការផ្សេងៗ អ្នកភូមិក៏ច្រើនមានការខ្វះខាតនិងខ្ចីប្រាក់គេសម្រាប់ចំណាយលើការធ្វើស្រែផងដែរ ដោយសង្ឃឹមថានឹងសងបំណុលនោះវិញនៅពេលប្រមូលផលស្រូវ។ ប៉ុន្តែនៅរដូវ ឬ ឆ្នាំខ្លះ ការធ្វើស្រែត្រូវជួប នឹងគ្រោះធម្មជាតិផ្សេងៗ ហើយដែលទិន្នផលស្រូវមិនអាចលក់សងបំណុលបាន នោះប្រជាជនក៏ត្រូវដោះស្រាយការសងបំណុលដោយមធ្យោបាយផ្សេងៗ ដូចជា ការធ្វើចំណាកស្រុករកការងារធ្វើ ឬ លក់ដីស្រែ ជាដើម ហើយករណីខ្លះ វាបានធ្វើឱ្យប្រជាជនកាន់តែប្រឈមនឹងភាពទីទាល់ក្រខ្លាំងឡើង។ ហេតុនេះ ការទទួលបានប្រាក់ចំណូលពីការធ្វើការងារនៅក្នុងសិប្បកម្មនេះ បានរួមចំណែកយ៉ាងសំខាន់ជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅក្នុងសហគមន៍។ ជាងនេះទៀត ម្ចាស់សិប្បកម្មក៏តែងផ្តល់លទ្ធភាពឱ្យកម្មករខ្ចីប្រាក់យកទៅសងដោះបំណុលគេជាមុន រួចទើបធ្វើការងារកាត់សងជំនួសជាក្រោយផងដែរ។

---

[9] ប៉ាត់ អាន អាយុ៤០ឆ្នាំ ជាកម្មករនៅក្នុងសិប្បកម្មនេះ រស់នៅក្នុងភូមិបឹងឈូក ឃុំបឹងបត់កណ្តាល ស្រុកបាកាន ខេត្តពោធិ៍សាត់ (សម្ភាសថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៩)។

[10] កម្មករជាមូលដ្ឋានគឺប្រជាជននៅក្នុងភូមិបឹងឈូក តែក៏មានកម្មករខ្លះមកពីភូមិក្បែរខាងនិងពីខេត្តដទៃដែរ។

[11] ភោគ ជួន អាយុ៥៤ ជាកម្មករនៅក្នុងសិប្បកម្មនេះ រស់នៅក្នុងភូមិបឹងឈូក ឃុំបត់កណ្តាល ស្រុកបាកាន ខេត្តពោធិ៍សាត់ (សម្ភាសថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៩)

ក្រៅពីនេះ កម្មករនិងប្រជាជនដទៃផ្សេងទៀតនៅក្នុងសហគមន៍ ក៏ទទួលបានផលបន្ថែមទៀតពីសិប្បកម្មនេះ ដោយការយកចម្រៀកឬចំនៀរត្នោតសល់ពីតម្រូវការធ្វើវត្ថុសម្ភារៈផ្សេងៗ ធ្វើជាឧសសម្រាប់ដុតចម្អិនអាហារប្រចាំថ្ងៃ និងបំពេញតម្រូវការផ្សេងទៀតផងដែរ។ លោក សាន ពៅ ជាម្ចាស់សិប្បកម្មបានលើកឡើងថា សូម្បីតែពេលពិធីបុណ្យឬពិធីមង្គលការ មិនថាប្រជាជនក្នុងភូមិឬមកពីភូមិដទៃទេ ទោះពួកគាត់មកសុំដឹកទាំងរទេះគោឬទាំងគោយន្ត ក៏លោកមិនបានយកថវិកាដែរ។ ដើមត្នោត ទោះមិនមានខ្លឹមក្តី ក៏វាដុតឆេះល្អ ហើយមានរងើកទៀតផង។


កម្មករសិប្បកម្មដឹកចំនៀរត្នោតសម្រាប់ធ្វើឧស


ចំនៀរត្នោតដែលអ្នកភូមិយកមកធ្វើជាឧស

## គំនិតគួរពិចារណា

ការលេចឡើងនូវវត្តមានសិប្បកម្មផលិតវត្ថុសម្ភារៈនានាអំពីខ្លឹមត្នោត បាននាំឱ្យមានទស្សនៈពីរមិនស្របគ្នា គឺទស្សនៈក្នុងន័យអភិរក្ស និង ទស្សនៈក្នុងន័យអភិវឌ្ឍន៍។ ទស្សនៈទី១ បានបង្ហាញអំពីក្តីបារម្ភចំពោះការបាត់បង់រុក្ខជាតិជានិមិត្តរូបរបស់ជាតិ(ដើមត្នោត)នាពេលអនាគត ហើយទស្សនៈទី២ បានលើកឡើងអំពីការផ្តល់ផលប្រយោជន៍របស់សិប្បកម្មដល់សង្គមជាតិ តាមរយៈការជួយពង្រឹងជីវភាព និងការកាត់បន្ថយការធ្វើចំណាកស្រុករបស់ប្រជាជននៅក្នុងសហគមន៍។ ទស្សនៈទាំងពីរនេះ សុទ្ធសឹងមានហេតុផលនិងមានតម្លៃគួរពិចារណាសម្រាប់ជាតិ។

ដើមត្នោតត្រូវបានចាត់បញ្ចូលជាប្រភេទរុក្ខជាតិនិមិត្តរូបមួយរបស់ជាតិខ្មែរ ហើយរាជរដ្ឋាភិបាលបានចេញបទបញ្ញានិងចាត់វិធានការផ្សេងៗដើម្បីការពារនិងអភិរក្សប្រភេទរុក្ខជាតិ (ដើមត្នោត) នេះ តាមរយៈការហាមឃាត់ចលនាកាប់ដើមត្នោតនិងការប្រមូលទិញជាលក្ខណៈប្រមូលផ្តុំ។ ចំណុចនេះ បានបង្ហាញឱ្យឃើញថា មានការព្រួយបារម្ភ និង ការយកចិត្តទុកដាក់នៅកម្រិតជាតិរួចហើយក្នុងការការពាររុក្ខជាតិអត្តសញ្ញាណជាតិ ដែលមានតម្លៃខាងវប្បធម៌ ប្រវត្តិសាស្ត្រ និង ទេសភាពធម្មជាតិ។

ជាការពិត ប្រសិនបើមានចលនាកាប់ដើមត្នោត និងការទិញដើមត្នោត ជាលក្ខណៈប្រមូលផ្តុំ និងជាប្រចាំ ដើម្បីជាវត្ថុធាតុដើមគាំទ្រដល់ការផលិតវត្ថុសម្ភារៈផ្សេងៗ នោះវានឹងធ្វើឱ្យដើមត្នោតប្រឈមនឹងការបាត់បង់នាពេលអនាគត។ ក្តីព្រួយបារម្ភនេះបានកើតមានជាពិសេសចំពោះសិប្បកម្មដែលមានទ្រង់ទ្រាយធំ ជាជាងការផលិតជាលក្ខណៈគ្រួសារ ព្រោះសិប្បកម្មទ្រង់ទ្រាយធំមានតម្រូវការវត្ថុធាតុដើមច្រើន និងជាប្រចាំសម្រាប់បម្រើការក្នុងការផលិត។ ប្រសិនបើដំណើរការសិប្បកម្ម ចេះតែបន្តទៅមុខ និងកាន់តែមានចំនួនច្រើន នោះតម្រូវការវត្ថុធាតុដើមក៏កាន់តែមានទំហំធំឡើង ហើយចលនាកាប់ដើមត្នោតក៏កាន់តែមានទ្រង់ទ្រាយធំទៅទៀត។

ទោះបីដើមត្នោតមានសភាពចាស់ទ្រុឌទ្រោម ប្រជាជនមិនអាចប្រើការទាញប្រយោជន៍បានទៀតក្តី តែបើមិនកាប់វាទេ នោះវានឹងនៅតែអាចបង្ហាញវត្តមានយូរអង្វែងតទៅមុខទៀត សម្រាប់អ្នកជំនាន់ក្រោយ។ ផ្ទុយទៅវិញ ប្រសិនបើយើងកាប់ដើមត្នោត ទោះបីក្នុងហេតុផលសមស្របក្តី នោះវានឹងធ្វើឱ្យបាត់បង់នូវរូបភាពដើមត្នោតជាក់ស្តែងពុំខាន ពោលគឺការកាប់ដើមត្នោតនឹងធ្វើឱ្យប៉ះពាល់ដល់បរិមាណដើមត្នោតនិងបាត់បង់រូបភាពដើមត្នោតនៅក្នុងប្រទេស។ ក្នុងន័យនេះ ទស្សនៈអភិរក្សហាក់មិនគាំទ្រឱ្យមានសិប្បកម្មផលិតវត្ថុសម្ភារៈផ្សេងៗពីខ្លឹមត្នោតឡើយ។

ដោយឡែក ក្នុងន័យអភិវឌ្ឍន៍ រាជរដ្ឋាភិបាលក៏មានការអនុញ្ញាតឱ្យមានការកែច្នៃដើមត្នោតជាលក្ខណៈប្រពៃណីនូវគ្រឿងចម្លាក់ សម្ភារៈប្រើប្រាស់ វត្ថុអនុស្សាវរីយ៍ និង ផលិតផលត្នោតកែច្នៃផ្សេងៗទៀត ប្រកបដោយការសន្សំសំចៃខ្ពស់ សម្រាប់បម្រើទីផ្សារ ក្នុងគោលបំណងបង្កើនមុខរបរជូនប្រជាពលរដ្ឋផងដែរ។

តាមលក្ខណៈបច្ចេកទេស ដើមត្នោតដែលអាចប្រើការកែច្នៃជាគ្រឿងវត្ថុសម្ភារៈផ្សេងៗបាន គឺលុះត្រាតែជាដើមត្នោតមានខ្លឹម ពោលគឺ គេកែច្នៃគ្រឿងវត្ថុសម្ភារៈផ្សេងៗពីខ្លឹមត្នោត មិនមែនពីគ្រប់ផ្នែកនៃដើមត្នោតនោះទេ។ ហេតុនេះគេមិនត្រូវការដើមត្នោតមិនមានខ្លឹមនោះឡើយ។ ជាទូទៅ ដើមត្នោតមានខ្លឹមល្អ សុទ្ធសឹងជាដើមត្នោតមានអាយុច្រើនរយឆ្នាំ មានដើមរាវតូចខ្ពស់ លែងមានផ្កា មានផ្លែ ឬលែងមានការលូតលាស់ ហើយអាចប្រឈមនឹងការបាក់ធ្លាក់ដោយប្រការផ្សេងៗដែលប្រជាជនលែងហ៊ានឡើងទាញយកប្រយោជន៍ទៀតហើយ។ និយាយរួម ដើមត្នោតមានខ្លឹមដែលអាចយកមកប្រើការកែច្នៃជាគ្រឿងវត្ថុសម្ភារៈផ្សេងៗបាន គឺភាគច្រើនជាប្រភេទដើមត្នោតដែលប្រជាជនស្ទើរតែលែងទាញប្រយោជន៍បាន។

ជាងនេះទៀត តាមការលើកឡើងរបស់ម្ចាស់សិប្បកម្ម ដើមត្នោតដែលបម្រើការកែច្នៃនៅក្នុងសិប្បកម្ម ភាគច្រើនជាដើមត្នោតបានមកពីការសុំឬទិញចំពោះដើមត្នោតដែលម្ចាស់ត្រូវកាប់ ឬ ឈូសចោលដោយ តម្រូវការពង្រីកដី ដោយការរាំងទើសផ្សេងៗ ដោយការប្រឈមនឹងការបង្កជាគ្រោះថ្នាក់ផ្សេងៗ ឬ ដោយ ត្រូវរន្ទះបាញ់ ជាដើម។ ហេតុនេះ ទោះបីជាសកម្មភាពនេះជាចំណែកមួយបានធ្វើឱ្យបាត់បង់ចំនួនដើម ត្នោតនៅក្នុងប្រទេសក្តី តែវាបានប៉ះពាល់តែដើមត្នោតដែលលែងប្រើការឬលែងមានប្រយោជន៍ប៉ុណ្ណោះ។ ប៉ុន្តែទន្ទឹមនោះ សិប្បកម្មបានជួយកាត់បន្ថយភាពក្រីក្រ ជួយពង្រីកជីវភាព និងជួយទប់ស្កាត់ការធ្វើ ចំណាកស្រុករបស់ប្រជាជននៅក្នុងសហគមន៍បានយ៉ាងច្រើន។

ក្រៅពីនេះ មានទិដ្ឋភាពផ្សេងទៀតដែលយើងគួរព្រួយបារម្ភអំពីកត្តាដែលនាំឱ្យបាត់បង់ដើមត្នោត នៅក្នុងប្រទេស នោះគឺ ការអភិវឌ្ឍដែលមានចលនាកាន់តែខ្លាំងឡើងៗ។ ដើមត្នោតជាច្រើនត្រូវកាត់ និង ដុតចោល ដើម្បីកែប្រែបរិវេណដីសម្រាប់បម្រើតម្រូវការផ្សេងៗ ដូចជា លំនៅដ្ឋាន ឬ ទីប្រកបរបរ អាជីវកម្មផ្សេងៗ។ ជាទូទៅ យើងឃើញដើមត្នោតទាំងនោះជាច្រើន ពុំត្រូវបានកែច្នៃជាវត្ថុសម្ភារៈសម្រាប់ ប្រើប្រាស់ជាប្រយោជន៍អ្វីឡើយ។ ការអភិវឌ្ឍនឹងមានចលនាកាន់តែខ្លាំងឡើងថែមទៀត ហើយតម្រូវការ នៃការកែប្រែដី ដែលនឹងធ្វើឱ្យបាត់បង់ដើមត្នោតនិងរុក្ខជាតិផ្សេងទៀត ក៏នឹងកាន់តែមានទំហំធំធេង ផងដែរ។



ដើមត្នោតដែលប្រជាជនកាប់និងអារចោលនៅតាមស្រែ

បន្ថែមលើទិដ្ឋភាពនេះ នៅតាមតំបន់ខ្លះ មានការកាត់ដើមត្នោតអាជាកង់ៗ ដើម្បីលក់ឱ្យប្រជាជន ដែលមានតម្រូវការសម្រាប់ជាគ្រឿងតាំងលម្អឬយកមករៀបធ្វើជាតុតូចៗ ដើម្បីតម្កល់នូវសម្ភារៈ

ដែលត្រូវតាំងលម្អផងដែរ ហើយដែលសកម្មភាពនេះមិនតម្រូវថាជាដើមត្នោតមានខ្លឹមឬគ្មានខ្លឹមនោះទេ តែគឺសំដៅលើដើមត្នោតទូទៅ។ សកម្មភាពនេះបានធ្វើឱ្យមានការព្រួយបារម្ភផងដែរ សម្រាប់ការបាត់បង់កាន់តែច្រើនឡើងនូវរុក្ខជាតិអត្តសញ្ញាណរបស់ជាតិ ព្រោះថាបើសកម្មភាពនេះកើតឡើងបន្ត វានឹងកាន់តែងាយបាត់បង់ដើមត្នោត ទាំងដើមត្នោតដែលមានអាយុច្រើន ទាំងដើមត្នោតដែលមានអាយុតិច។

ជារួម កត្តាទាំងអស់នេះសុទ្ធតែរួមចំណែកដល់ការធ្វើឱ្យបាត់បង់ដើមត្នោតដូចគ្នា គ្រាន់តែតិច និងច្រើនប៉ុណ្ណោះ។ ប៉ុន្តែ ប្រសិនបើយើងប្រៀបធៀបសកម្មភាពនៃការកាប់ដើមត្នោតទាំងអស់ខាងលើនេះ យើងឃើញថាការកាប់ដើមត្នោតមានខ្លឹមសម្រាប់កែច្នៃជាវត្ថុសម្ភារៈផ្សេងៗ គួរទទួលបានការគាំទ្រ និងលើកទឹកចិត្ត ព្រោះគេកាប់ដើមត្នោតដែលលែងប្រើជាប្រយោជន៍បាន ហើយវាបានជួយដល់ការពង្រឹងជីវភាពប្រជាជនក្នុងសហគមន៍ទៀតផង។

## សេចក្តីសន្និដ្ឋាន

ដើមត្នោតត្រូវបានចាត់បញ្ចូលជាប្រភេទរុក្ខជាតិនិមិត្តរូបមួយរបស់ជាតិខ្មែរ ហេតុនេះសកម្មភាពមិនសមស្របទាំងឡាយដែលនាំទៅរកការបំផ្លាញដើមត្នោតជាគំហុក អាជ្ញាធរត្រូវចាត់វិធានការទប់ស្កាត់តាមផ្លូវច្បាប់ និងផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋឱ្យយល់ដឹងកាន់តែស៊ីជម្រៅអំពីតម្លៃនិងសារប្រយោជន៍យូរអង្វែងនៃដើមត្នោត ទាំងខាងតម្លៃវប្បធម៌ អរិយធម៌ ប្រវត្តិសាស្ត្រធម្មជាតិ និង ជីវភាព។

ជាការពិត មានករណីខ្លះគឺតម្រូវឱ្យយើងចាំបាច់ត្រូវកាប់ដើមត្នោតចោលដោយក្នុងគោលបំណងសមហេតុផល ដូចជា ដោយតម្រូវការអភិវឌ្ឍផ្សេងៗ ការធ្វើលំនៅដ្ឋាន ការពង្រីកដីធ្វើកសិកម្ម ការពង្រីកដីធ្វើអាជីវកម្ម ឬ ករណីចាំបាច់ដោយឡែកទៀត។ ប៉ុន្តែ ការអភិរក្សនិងការអភិវឌ្ឍគួរដើរទន្ទឹមគ្នា ដោយមិនអាចផ្តោតតែលើការអភិរក្ស ហើយបោះបង់ការអភិវឌ្ឍ ឬ ផ្តោតតែលើការអភិវឌ្ឍ ហើយបោះបង់ការអភិរក្សនោះឡើយ។ ដំណើរការសិប្បកម្មបានរួមចំណែកជួយដល់សហគមន៍យ៉ាងច្រើន តែការកាប់និងការទិញដើមត្នោត ក៏គួរមានការគ្រប់គ្រងនិងត្រួតពិនិត្យឱ្យបានត្រឹមត្រូវផងដែរ។

## បទសម្ភាសន៍

- គឿន មិកា អាយុ១៦ឆ្នាំ និង ម៉ន សុខ រីម អាយុ១៧ឆ្នាំ ជាកម្មករធ្វើការក្នុងសិប្បកម្ម រស់នៅក្នុងភូមិត្រពាំងអំពិល ស្រុកបាកាន ខេត្តពោធិ៍សាត់ (សម្ភាសថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៩)
- ប៉ាត់ អាន អាតុ៤០ឆ្នាំ ជាកម្មករធ្វើការក្នុងសិប្បកម្ម រស់នៅក្នុងភូមិបឹងឈូក ឃុំបត់កណ្តោល ស្រុកបាកាន ខេត្តពោធិ៍សាត់ (សម្ភាសថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៩)

- ផាន គឿន អាយុ៤៣ឆ្នាំ ជាភរិយារបស់លោក សាន ពៅ (ម្ចាស់សិប្បកម្ម) រស់នៅក្នុងភូមិបឹងឈូក ឃុំបត់កណ្តោល ស្រុកបាកាន ខេត្តពោធិ៍សាត់ (សម្ភាសថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៩)
- ភោគ ជួន អាយុ៥៤ឆ្នាំ ជាកម្មករធ្វើការក្នុងសិប្បកម្មនេះ រស់នៅក្នុងភូមិបឹងឈូក ឃុំបត់កណ្តោល ស្រុកបាកាន ខេត្តពោធិ៍សាត់ (សម្ភាសថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៩)
- សាន ពៅ អាយុ៤១ឆ្នាំ ជាម្ចាស់សិប្បកម្ម រស់នៅក្នុងភូមិបឹងឈូក ឃុំបត់កណ្តោល ស្រុកបាកាន ខេត្តពោធិ៍សាត់ (សម្ភាសថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៩)
- ស្រី ហៃ ភេទស្រី អាយុ៤៩ឆ្នាំ ជាកម្មករធ្វើការក្នុងសិប្បកម្ម រស់នៅក្នុងភូមិបឹងឈូក ឃុំបត់កណ្តោល ស្រុកបាកាន ខេត្តពោធិ៍សាត់ (សម្ភាសថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៩)



សកម្មភាពសម្ភាសជាមួយលោក សាន ពៅ (ម្ចាស់សិប្បកម្ម)



អ្នកស្រាវជ្រាវនិងសិប្បការិនីនៅក្នុងសិប្បកម្ម សាន ពៅ